**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ២០៦៥ ព.ណ..ភបស.

ថ្ងៃ សុក្រ ១១រោច ខែ ស្រាពណ៍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០២១

**<u>ជម្រាបមក</u>**

**លោក/លោកស្រីប្រធានក្រុមហ៊ុន ចូតាន់ (ខេមបូឌា) អិលធីឌី**

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផល (១) ផលិតផលគីមី សម្រាប់ប្រើក្នុងឧស្សាហកម្ម ការសិប្បនិម្មិតនិងសំយោគ ប្លាស្ទិចនៅក្នុងទំរង់ជាម្សៅ សមាសភាពទន់ រាវ ការបែងចែក emulsions ឬការច្របាច់បញ្ចូលគ្នា សម្រាប់ប្រើក្នុងការផលិត សារធាតុស្អិតសម្រាប់ប្រើក្នុងឧស្សាហកម្ម ផលិតផលគីមីសម្រាប់ប្រើប្រាស់លើវិស័យឧស្សាហកម្មក្នុងទម្រង់ជាម្សៅស្ងួតដោយកំដៅដោយមូលដ្ឋានគ្រឹះនៃ polyester អ៊ីប៉ុកស៊ី ប៉ូលីមើរ ហ្សូប៉ូលីមើរ ឬប៉ូលីយូរីថេន សម្រាប់ការការពារនិងការតុបតែងលម្អផ្ទៃនៃផលិតផលដែក ផលិតផលប្លាស្ទិច ផលិតផលMDF (ផលិតផលដែល មានដង់ស៊ីតេមធ្យម Fibreboard-products) និងផលិតផលធ្វើពីឈើផ្សេងៗ។ (២) ផលិតផលថ្នាំលាប វ៉ារនីស ថ្នាំកូតម្រ័ក្សណ៍ខ្មុក ថ្នាំការពារកឹងសម្រាប់ទូក កប៉ាល់ ការរុករក និងទាញយកប្រេងនិងឧស្ម័នពីក្រោមបាតសមុទ្រ ផលិតផលការពារច្រេះ និងការពារឈើ ថ្នាំកូត(ក្នុងទម្រង់ជាថ្នាំលាបទូទៅ) សម្រាប់ទូក កប៉ាល់ ការរុករក និងទាញយកប្រេង និងឧស្ម័នពីក្រោមបាតសមុទ្រ ម្សៅវ៉ានីស ម្សៅវ៉ានីសសម្រាប់ការពារ និងតុបតែងលម្អផ្ទៃនៃផលិតផលដែក ផលិតផលប្លាស្ទិច ផលិតផលMDF (ផលិតផលដែលមានដង់ស៊ីតេមធ្យម Fibreboard-products) និងផលិតផលធ្វើពីឈើផ្សេងៗម៉ាក JOTUN របស់ក្រុមហ៊ុន **ចូតាន់ (ខេមបូឌា) អិលធីឌី** ក្នុងព្រះរាជាណាចក្រកម្ពុជា។

**យោង:**- មាត្រា ៣ និងមាត្រា ១១នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **ចូតាន់ (ខេមបូឌា) អិលធីឌី** ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០២១
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន JOTUN AS ចុះថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០២១
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី M/១០៨៣៤៦២/១៧ ចុះថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០១៧។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផល(១) ផលិតផលគីមី សម្រាប់ប្រើក្នុង ឧស្សាហកម្ម ការសិប្បនិម្មិតនិងសំយោគ ប្លាស្ទិចនៅក្នុងទំរង់ជាម្សៅ សមាសភាពទន់ រាវ ការបែងចែក emulsions ឬការច្របាច់បញ្ចូលគ្នាសម្រាប់ប្រើក្នុងការផលិត សារធាតុស្អិតសម្រាប់ប្រើក្នុងឧស្សាហកម្ម ផលិតផលគីមីសម្រាប់ ប្រើប្រាស់លើវិស័យឧស្សាហកម្មក្នុងទម្រង់ជាម្សៅស្ងួតដោយកំដៅដោយមូលដ្ឋានគ្រឹះនៃ polyester អ៊ីប៉ុកស៊ី ប៉ូលីមើរ ហ្សូប៉ូលីមើរ ឬប៉ូលីយូរីថេន សម្រាប់ការការពារ និងការតុបតែងលម្អផ្ទៃនៃផលិតផលដែក ផលិតផលប្លាស្ទិច ផលិតផលMDF (ផលិតផលដែលមានដង់ស៊ីតេមធ្យម Fibreboard-products) និងផលិតផលធ្វើពីឈើផ្សេងៗ។ (២) ផលិតផលថ្នាំលាប វ៉ារនីស ថ្នាំកូតម្រ័ក្សណ៍ខ្មុក ថ្នាំការពារកឹងសម្រាប់ទូក កប៉ាល់ ការរុករក និងទាញយកប្រេងនិងឧស្ម័នពីក្រោមបាតសមុទ្រ ផលិតផលការពារច្រេះ និងការពារឈើ ថ្នាំកូត(ក្នុងទម្រង់ជាថ្នាំលាបទូទៅ) សម្រាប់ទូក កប៉ាល់ ការរុករក និងទាញយកប្រេង និងឧស្ម័នពីក្រោមបាតសមុទ្រ ម្សៅវ៉ានីស ម្សៅវ៉ានីសសម្រាប់ការពារ និងតុបតែងលម្អផ្ទៃនៃផលិតផលដែក ផលិតផលប្លាស្ទិច ផលិតផលMDF (ផលិតផលដែលមានដង់ស៊ីតេមធ្យម Fibreboard-products) និងផលិតផលធ្វើពីឈើផ្សេងៗពាក់ម៉ាកខាងលើ របស់ក្រុមហ៊ុន **ចូតាន់ (ខេមបូឌា) អិលធីឌី** ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានពីក្រុមហ៊ុន JOTUN AS ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខដែលក្រសួងបានតម្កល់ទុករួចហើយ។

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

លិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខនេះមានសុពលភាព ០២(ពីរ)ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិមុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន JOTUN AS ដែលជាម្ចាស់ម៉ាក។

ចាប់ពីក្រោយរយៈពេល ៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខនេះអ្នកទទួលសិទ្ធិស្របច្បាប់មានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវផ្សព្វផ្សាយលិខិតខាងលើនេះជាបន្ទាន់ក្នុងទំព័រខាងមុខរបស់សារព័ត៌មានក្នុងព្រះរាជាណាចក្រកម្ពុជា និងបណ្តាញសង្គមនានា និងត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

អ៊ុក_ប្រុជា

*ចម្លងជូន:*

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចក្រឡាហោម **ស ខេង***
- *ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប)*
- *អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ - កាលប្បវត្តិ*